ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានបើកសិក្ខាសាលាស្តីពី **“ពន្ធលើប្រាក់ចំណេញ និងរបៀបបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ”** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានជាច្រើនរូប ព្រមទាំងមានការចូលរួមពីសំណាក់លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាអភិបាល បណ្ណាធិការ តំណាងសហគ្រាស ប្រមាណជាជាង ៤០០ សហគ្រាស។



ជាកិច្ចចាប់ផ្តើម ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងនូវអំណរគុណចំពោះលោកជំទាវ លោកឧកញ៉ា លោក-លោកស្រី នាងកញ្ញា ជាអភិបាល បណ្ណាធិការ និងជាតំណាងរោងចក្រ សហគ្រាសនានា ដែលមានវត្តមានចូលរួមនៅក្នុងអង្គសិក្ខាសាលាដ៏មានសារសំខាន់នេះ ដែលសបញ្ជាក់ឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពប្រតិបត្តិច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ជាពិសេស គឺដើម្បីស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ របស់ខ្លួន។ សិក្ខាសាលាដ៏មានសារសំខាន់នេះ នឹងរួមចំណែកខ្ពស់ក្នុងការពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធ ហើយតាមរយៈសិក្ខាសាលានេះ សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត ស្តីពីពន្ធលើប្រាក់ចំណេញ និងនីតិវិធីនៃការបំពេញលិខិតប្រកាសបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជម្រាបជូនអង្គសិក្ខាសាលាថា នេះគឺជាសិក្ខាសាលាលើកទីមួយបង្អស់សម្រាប់ឆ្នាំ២០១៥ ដែលត្រូវបានរៀបចំឡើងដោយអគ្គនាយកដ្ឋានពន្ធដារ ស្របពេលដែលរដូវកាលនៃការដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤ បានឈានចូលមកដល់។ រដូវកាលនៃការប្រកាសបង់ពន្ធនេះ គឺចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងត្រូវបិទបញ្ចប់ទៅវិញនៅថ្ងៃទី៣១ ខែមីនា ខាងមុខ។ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញនេះ មានចែងក្នុងជំពូក ១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ តម្រូវឲ្យអ្នកជាប់ពន្ធជានិវាសនជនដែលមានប្រភពចំណូលកម្ពុជា និងប្រភពចំណូលបរទេស និងអនិវាសនជនដែលមានប្រភពចំណូលកម្ពុជា ត្រូវជាប់កាតព្វកិច្ចបង់ពន្ធប្រភេទនេះ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានបញ្ជាក់ជូនអង្គសិក្ខាសាលាយ៉ាងដូច្នេះថា ក្នុងបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន (AEC)ដែលនឹងខិតចូលមកដល់ បន្ទុកនៃការប្រមូលចំណូលពន្ធ នឹងត្រូវធ្លាក់មកលើផ្នែកប្រមូលចំណូលពន្ធផ្ទៃក្នុងកាន់តែច្រើនឡើងៗ។ ក្នុងបរិបទជាក់លាក់បែបនេះ អគ្គនាយកពន្ធដារត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីប្រមូលចំណូលពន្ធឲ្យបានគ្រប់តាមផែនការច្បាប់។ ប្រការនេះតម្រូវឲ្យអគ្គនាយកដ្ឋានពន្ធដារខិតខំផ្តោតការយកចិត្តទុក ដាក់ខ្ពស់លើការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលមានជាធរមាន តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ទាំងវិធានការច្បាប់និងវិធានការរដ្ឋបាល ចំពោះការគេចវេះពន្ធ ការលួចបន្លំពន្ធតាមគ្រប់រូបភាព ដើម្បីធានាបាននូវបរិយា-កាសធុរកិច្ច និងការប្រកួតប្រជែងដោយស្មើភាពគ្នាចំពោះគ្រប់ធុរជន ក្នុងគោលដៅប្រមូលចំណូលពន្ធ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសមធម៌។

ព្រមជាមួយនេះ ការលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌ពន្ធដារឲ្យបានជ្រួតជ្រាបដល់គ្រប់មជ្ឈដ្ឋានអ្នកជាប់ពន្ធ បន្តកែលម្អអភិបាលកិច្ចរបស់រដ្ឋបាលសារពើពន្ធ ព្រមទាំងបន្ត ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារក្នុងចំណោមមន្ត្រីពន្ធដារគ្រប់រូបនិងគ្រប់លំដាប់ថ្នាក់ ពង្រឹងសមត្ថភាព និងកែប្រែផ្នត់គំនិត (Mindset) របស់មន្ត្រីពន្ធដារ ឲ្យខិតខំយកចិត្តទុកដាក់អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងមានទំនួលខុសត្រូវខ្ពស់ ដោយឈរលើមនសិការ ស្មារតីតម្កល់ផលប្រយោជន៍ជាតិជាចម្បង។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជម្រាបជូនអង្គសិក្ខាសាលាផងដែរថា ក្នុងពេលឆាប់ៗខាងមុខនេះ អគ្គនាយកដ្ឋានពន្ធដារនឹងដាក់ឲ្យដំណើរការ ការដាក់លិខិតប្រកាសបង់ពន្ធតាមប្រព័ន្ធអេឡិកត្រូនិក (E-Filing) ដែលនេះជាផ្នែកមួយនៃការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការផ្តល់សេវា បង្កលក្ខណៈងាយស្រួលជូនអ្នកជាប់ពន្ធ កាត់បន្ថយបានការចំណាយពេលវេលា និងនីតិវិធីនៃការប្រកាស់បង់ពន្ធ របស់ពួកគាត់។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ការចូលរួមពីសំណាក់អ្នកជាប់ពន្ធគឺជាកិច្ចការចាំបាច់ដោយខានមិនបាន។ ការផ្តល់កិច្ចសហការខ្ពស់ពីសំណាក់អ្នកជាប់ពន្ធ ការគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិស្តីពីពន្ធដារ គឺជាកិច្ចការចម្បងដែលអ្នកជាប់ពន្ធគ្រប់រូបត្រូវប្រកាន់យក ហើយត្រូវបោះបង់ចោលនូវទម្លាប់ចាស់ ដែលកន្លងមកតែងតែស្នើសុំលើកលែងពន្ធ ដោយលើកយកហេតុផលផ្សេងៗ និងប្រែក្លាយការគោរពប្រតិបត្តិច្បាប់មិនទាន់បានខ្ជាប់ខ្ជួន និងមិនទាន់បានត្រឹមត្រូវ ឲ្យមកជាការគោរពប្រតិបត្តិច្បាប់ប្រកបដោយខ្ជាប់ខ្ជួន និងត្រឹមត្រូវ ដោយមកដាក់លិខិតប្រកាស និងបង់ពន្ធឲ្យបានទាន់ពេលវេលា និងឲ្យបានត្រឹមត្រូវ។

ឯកឧត្តមបានផ្តាំផ្ញើជូនសិក្ខាកាម ឲ្យខិតខំត្រងត្រាប់ស្តាប់បទបង្ហាញរបស់គ្រូឧទ្ទេសនាម ដើម្បីបានយល់ដឹងកាន់តែច្បាស់នូវនីតិវិធីនៃការដាក់លិខិតប្រកាសបង់ពន្ធ ហើយសង្ឃឹមថា អស់លោក-លោកស្រី នាងកញ្ញា ជាអភិបាល

បណ្ណាធិការ និងតំណាងសហគ្រាស នឹងមកដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤ បានគ្រប់ៗគ្នា បានទាន់ពេលវេលា និងប្រកបដោយតម្លាភាព ព្រមទាំងបន្តផ្តល់កិច្ចសហការខ្ពស់ បង្កើតវប្បធម៌ជជែកពិភាក្សា ផ្តល់យោបល់ ផ្តល់ការរិះគន់ក្នុងន័យស្ថាបនាគ្នាទៅវិញទៅមក ដើម្បីអភិវឌ្ឍសមត្ថភាព ទាំងរដ្ឋបាលសារពើពន្ធ ទាំងអ្នកជាប់ពន្ធ ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់យើងទាំងអស់គ្នា នៅក្នុងក្របខ័ណ្ឌនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ក៏ដូចជាក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក។



ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជូនពរ ឯកឧត្តម-លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី និងសិក្ខាកាមទាំងអស់ សូមសមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរឲ្យអង្គសិក្ខាសា លា នាថ្ងៃនេះ ប្រព្រឹត្តទៅប្រកបដោយលទ្ធផលជាផ្លែផ្កា គួរជាទីពេញចិត្ត។